# ការចងចាំ និងតុលាការកាត់ទោសខ្មែរក្រហម


១. សេចក្តីផ្តើម ....................

២. ការចងចាំពីរបបខ្មែរក្រហមស្ថិតនៅជាដរាប ....................

៣. គំនិតក្មេងជំនាន់ក្រោយមួយរូបទាក់ទងនឹងសាលាក្តីខ្មែរក្រហម ....................

៤. ឪពុករបស់ខ្ញុំ និងការជំនុំជម្រះក្តីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ....................


## ១. សេចក្តីផ្តើម

អត្ថបទនេះតាក់តែងឡើង ដោយរួមបញ្ចូលសំណេរចំនួនបីរបស់នារីខ្មែរបីរូប ក្នុងគោលបំណងឆ្លុះបញ្ចាំងពីបទពិសោធន៍ ដែលសមាជិកគ្រួសារអ្នកទាំងបីបានជួបប្រទះក្នុងសម័យខ្មែរក្រហម ព្រមទាំងបង្ហាញពីប្រតិកម្មទៅលើកិច្ចប្រឹងប្រែងរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតទៅលើឧក្រិដ្ឋកម្មនាពេលនោះ ។ រហូតមកទល់នឹងពេលនេះ អង្គជំនុំជម្រះវិសមញ្ញតុលាការកម្ពុជាបានបើកធ្វើការជំនុំជម្រះសំណុំរឿងចំនួនពីរ និងធ្វើការកាត់ទោស កាំង ហ្គេកអ៊ាវ ហៅ ឌុច មេដឹកនាំនៅមន្ទីរសន្តិសុខស-២១ ឲ្យជាប់ពន្ធនាគារអស់មួយជីវិតចំពោះការសម្លាប់ និងធ្វើទារុណកម្មទៅលើមនុស្សចំនួន១ម៉ឺន២ពាន់នាក់ ។ សាលក្រមក្នុងការកាត់ក្តីមេដឹកនាំខ្មែរក្រហម ដែលនៅរស់រានមានជីវិតពីររូបទៀត អាចនឹងបញ្ចប់នៅពាក់កណ្តាលឆ្នាំ២០១៤ ខាងមុខនេះ ។

អ្នកទាំងបីដែលបានតាក់តែងសំណេរនេះ និងគ្រួសាររបស់ខ្លួនមកពីផ្នែកផ្សេងៗនៃសង្គមកម្ពុជា ។ អ្នកទាំងបីបានផ្តល់នូវទស្សនវិស័យទៅលើរបបខ្មែរក្រហម និងទៅលើសមត្ថភាពរបស់សាលាក្តីខ្មែរក្រហមក្នុងការផ្តល់នូវវិធានការយុត្តិធម៌ដល់អ្នកទាំងឡាយដែលនៅរស់រានមានជីវិត ។ អ្នកតាក់តែងសំណេរទីមួយឈ្មោះ សា ហ្វាទីលី ជាសមាជិកនៃសមាគមខ្មែរ-អ៊ិស្លាម ។ ខ្មែរ-អ៊ិស្លាម គឺជាក្រុមជនជាតិភាគតិច និងក្រុមសាសនាមួយដែលស្ថិតនៅក្រោមគោលដៅសម្លាប់របស់ខ្មែរក្រហម ។ ការ

សម្លាប់នេះគឺជាផ្នែកមួយនៃគោលនយោបាយប្រល័យពូជសាសន៍របស់ខ្មែរក្រហម ។[១] ហ្សាទីលី បានធ្វើការនៅក្នុងអង្គការកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំ ក្នុងការរក្សាទុកនូវឯកសារទាក់ទងនឹងសម័យខ្មែរក្រហម និងរឿងរ៉ាវរបស់អ្នកដែលនៅរស់រានមានជីវិត ព្រមទាំងធ្វើការលើកកម្ពស់នូវការទទួលខុសត្រូវទៅលើឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ។

អ្នកតាក់តែងសំណេរទីពីរឈ្មោះ ភូល ស្រីនាថ រស់នៅសហរដ្ឋអាមេរិកតាំងពីអាយុ១៨ឆ្នាំ ។ នាពេលថ្មីៗនេះ ស្រីនាថ បានត្រលប់មកទឹកដីកំណើតវិញ មុនពេលបន្តការសិក្សា នៅថ្នាក់ក្រោយបញ្ចប់បរិញ្ញាបត្រ ។ គ្រួសាររបស់ ស្រីនាថ ក៏ដូចជាគ្រួសាររបស់ សា ហ្សាទីលី រួមមាន មន្ត្រីរាជការនៃសម័យ លន់ នល់ ដែលជាក្រុមអ្នកនយោបាយស្ថិតនៅក្រោមគោលដៅសម្លាប់របស់ខ្មែរក្រហមដែរ ។[២]

អ្នកតាក់តែងសំណេរទីបីឈ្មោះ ហ៊ុយ សេងហ៊ុល ជាកូនស្រីរបស់ ហ៊ឹម ហ៊ុយ មេកងទទួលខុសត្រូវក្នុងការបញ្ជូនអ្នកទោសស-២១ ទៅសម្លាប់នៅវាលពិឃាដជើងឯក ។[៣] ហ៊ឹម ហ៊ុយ ស្ម័គ្រចិត្តនិយាយពីបទពិសោធន៍ផ្ទាល់ខ្លួនជាសាធារណៈ ដោយគាត់បានប្រាប់ថា“រូបគាត់បានកត់ត្រាឈ្មោះរបស់អ្នកទោសនៅក្នុងបញ្ជីមុនពេលដែលអ្នកទាំងអស់នោះត្រូវយកទៅសម្លាប់” ។[៤] ហ៊ឹម ហ៊ុយ សារភាពថាស្ថិតក្រោមការបង្ខិតបង្ខំរូបគាត់ផ្ទាល់ ក៏បានសម្លាប់មនុស្សពីប្រាំនាក់ទៅដប់នាក់ដែរ ក្នុងចំណោមជនរងគ្រោះរាប់ពាន់នាក់ ។[៥] ការសារភាពនេះបានជួយជំរុញទៅលើការផ្តន្ទាទោស ឌុច ដោយ ហ៊ឹម ហ៊ុយ បានអះអាងថា ឌុច គឺជាអ្នកទទួលខុសត្រូវធំបំផុតចំពោះឧក្រិដ្ឋកម្មដែលកើតមានឡើងនៅឯមន្ទីរស-២១ ។ ហ៊ឹម ហ៊ុយ លើកឡើងថាការចូលរួមក្នុងការសម្លាប់បានធ្វើឲ្យគាត់បាត់បង់នូវតម្លៃ និងសេចក្តីថ្លៃថ្នូរ ព្រមទាំងរស់នៅក្រោមការសង្ស័យ និងការស្អប់ខ្ពើមពីសហគមន៍របស់គាត់ ។ គាត់មានទស្សនៈថា ការវិនិច្ឆ័យ និងការផ្តន្ទាទោស ឌុច បានជួយឲ្យអ្នកជិតខាងរបស់គាត់យល់ដឹងថា គាត់មិន

---

[១] ដីកាដំណោះស្រាយនៃសំនុំរឿង០០២,សំនុំរឿងលេខ០០២/១៩-២០០៧-អ.វ.ត.ក - ក.ស.ប.ស, ¶¶ ៧៨៥-៧០, ១៣៣៦-៤២ (១៥ កញ្ញា ២០១០).

[២] មើលឧទាហរណ៍ខាងលើ ¶¶ ២៣៨-៣៥, ២៨៣, ២៥៤, ៣០៩, ៤៧៩, ៦៩៥, ៧០៧, ៩៧៧.

[៣] សាលក្រមជំនុំជម្រះក្តីរបស់ឌុច, សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/TC, ¶ ១៥៨ (២៦ កក្កដា ២០១០).

[៤] ដូចខាងលើ., ¶ ៤៨ n.២២៤; ដីកាដំណោះស្រាយនៃសំណុំរឿង០០២, ¶ ៤៦៤.

[៥] មើលសាវីណា ស៊ីរី,សាលក្រមបញ្ចប់របស់ឌុច: *Justice and Humanity* (មជ្ឈមណ្ឌលឯកសារកម្ពុជា,at ៥-៦ (២-៣ កុម្ភៈ ២០១២), នៅគេហទំព័រ http://www.d.dccam.org/Projects/Living_Doc/ECCC_Tour_and_Field_Trip_Reports.htm

មែនជាអ្នកគ្រប់គ្រងគុកនោះទេ ។ រូបគាត់គ្រាន់តែជាកម្មាភិបាលថ្នាក់ទាបម្នាក់ប៉ុណ្ណោះ ។ រូបគាត់ផ្ទាល់ក៏បានរស់នៅក្រោមភាពភ័យខ្លាចនៅក្នុងសម័យខ្មែរក្រហមដែរ ។[៦] ទស្សនៈរបស់ ហុយ សេងហ៊ុល គឺដូចទៅនឹងអ្នកគាក់តែងសំណេរដទៃទៀតដែរ ពោលគឺ ទស្សនៈនេះបានឆ្លុះបញ្ចាំងអំពីការចងចាំរបស់សមាជិកគ្រួសាររបស់គាត់ដែលបានឆ្លងកាត់របបខ្មែរក្រហម ។

## ២. ការចងចាំពីរបបខ្មែរក្រហមស្ថិតនៅជាដរាប

សា ហ្វាទីលី[៧]

មនុស្សម្នាក់ៗតែងតែមានការចងចាំរៀងៗខ្លួន មិនថាការចងចាំនោះមានភាពផ្អែមល្ហែម ឬជូរចត់ទេ ។ អ្នកដែលធ្វើឲ្យយើងចងចាំជាងគេ គឺជាអ្នកដែលធ្វើឲ្យយើងភ័យខ្លាចជាងគេ ។ នៅក្នុងជម្រៅចិត្តរបស់ប្រជាជនកម្ពុជា អ្នកដែលធ្លាប់រងការឈឺចាប់ពីវិនាសកម្មប្រវត្តិសាស្ត្រ និងឆ្លងកាត់ផ្ទាល់ពីរបបបីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃនេះ គឺមានការចងចាំដ៏គួរឲ្យភ័យខ្លាចដែលតាមលងបន្លាច ប្រជាជនកម្ពុជារាល់ថ្ងៃ ។ ជារៀងរាល់ថ្ងៃនៅក្រោមរបបដ៏សាហាវយង់ឃ្នង ប្រជាជនកម្ពុជាតែងតែបន់ស្រន់សូមឲ្យថ្ងៃនេះកន្លងផុតទៅឲ្យឆាប់រហ័ស ហើយសង្ឃឹមថានឹងឃើញព្រះអាទិត្យរះនៅថ្ងៃស្អែកបន្តទៀត ។

ពេលខ្លះ ការចងចាំទាំងអស់នេះបានធ្វើឲ្យជនរងគ្រោះស្រក់ទឹកភ្នែកដោយមិនដឹងខ្លួន ហើយថែមទាំងធ្វើឲ្យមានជំងឺភ័យខ្លាច និងជំងឺផ្លូវចិត្តទៀតផង ។ មនុស្សមួយចំនួនព្យាយាមស្វែងរកវិធីដែលអាចជួយឲ្យខ្លួនបំភ្លេចអតីតក្រោយរបបខ្មែរក្រហម ប៉ុន្តែខ្ញុំនៅតែមិនជឿថា ការបំភ្លេចអតីតកាលអាចជួយឲ្យប្រជាជនកម្ពុជាគេចផុតពីការពិតទាំងនេះបានឡើយ ។

តាមគំនិតខ្ញុំ ប្រជាជនកម្ពុជាមិនទំនងជាអាចបំភ្លេចនូវការចងចាំពីរបបខ្មែរក្រហមបាននោះទេ ។ ខ្ញុំបានធ្វើការលើកម្រោងជាច្រើននៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយដែលភាគច្រើនទាក់ទងនឹងវីដេអូបទសម្ភាសន៍ និងភាពយន្តឯកសារខ្មែរក្រហម ។ ការចាប់យករូបភាពវីដេអូសវនាការ ថតរូបភាគីក្នុងតុលាការ និងផលិតជាខ្សែភាពយន្តខ្លីៗស្តីពីប្រតិកម្មរបស់ប្រជាជនចំពោះការកាត់ក្តីនេះ ជាផ្នែកមួយនៃការងាររបស់ខ្ញុំចាប់ពីឆ្នាំ២០០៧មក ។ យោងតាមប្រតិកម្មរបស់ប្រជាជនកម្ពុជាដែលខ្ញុំបានជួបសម្ភាស ខ្ញុំដឹងថា អ្នកទាំងនោះមិនអាចបំភ្លេចរឿងរ៉ាវអតីតកាលបានទេ ។ ការបាត់បង់មនុស្ស ជាទីស្រលាញ់

---

[៦] ដូចខាងលើ

[៧] សា ហ្វាទីលី គឺជាអ្នករក្សាទុកឯកសារកុន ធ្វើការលើកម្រោងអត្តសញ្ញាណជនជាតិចាម នៅមជ្ឈមណ្ឌលឯកសារកម្ពុជា

និងអនុស្សាវរីយ៍ទាំងប៉ុន្មានដែលបានធ្លាប់ជួបប្រទះ គឺនៅតែដក់ជាប់ជានិច្ចនៅក្នុងក្រអៅបេះដូងរបស់គាត់ ។

ឪពុករបស់ខ្ញុំ សា ម៉ាត់ បានប្រាប់ខ្ញុំថា គាត់មិនអាចបំភ្លេចនូវអ្វីដែលឪពុកម្តាយគាត់ត្រូវបានសម្លាប់យ៉ាងព្រៃផ្សៃនៅក្នុងរបបខ្មែរក្រហមនោះឡើយ ។ ជារៀងរាល់ពេលដែលឪពុកខ្ញុំឃើញត្រសក់ត្រាំ គាត់តែងតែនឹកដល់ម្តាយរបស់គាត់ដែលតែងតែវេចខ្ចប់បាយជាមួយនឹងត្រសក់ត្រាំឲ្យគាត់ទៅសាលារៀន ។ របបខ្មែរក្រហមបានបំបែក និងជម្លៀសឪពុកខ្ញុំចេញពីអ្នកមានគុណរបស់គាត់ ។ នៅចុងឆ្នាំ១៩៧៥ របបនេះបានឆក់យកជីវិតមនុស្សជាទីស្រឡាញ់និងសាច់ញាតិរបស់យើង ដោយចោទថាបានចូលរួមក្នុងចលនាបះបោរជាមួយជនជាតិចាមនៅកោះផល ហើយប្រជាជនប្រមាណ ជិត១០០គ្រួសារ ត្រូវបាននាំយកទៅសម្លាប់ទាំងអស់ ។ ខ្មែរក្រហមបានសម្លាប់ជីតារបស់ខ្ញុំ និងប្អូនរបស់គាត់ដោយចងទម្ងាក់ទៅក្នុងទឹកដើម្បីឲ្យលង់ទឹកស្លាប់ ។ យាយរបស់ខ្ញុំស្លាប់ដោយសារតែមិនមានថ្នាំព្យាបាលជំងឺ ហើយឪពុករបស់ខ្ញុំនៅរស់ដោយសារគាត់ប្រឹងប្រែងធ្វើការ និងលាក់ប្រវត្តិរូបរបស់គាត់ដែលជាអតីតទាហាន លន់ នល់ ។

មានថ្ងៃមួយ ឪពុករបស់ខ្ញុំត្រូវបានចោទប្រកាន់ថាជាទាហាន លន់ នល់ ហើយគាត់បានព្យាយាមនិយាយបញ្ចុះបញ្ចូលកម្មាភិបាលទាំងអស់នោះថា គាត់គ្រាន់តែជាកសិករម្នាក់ដែលមិនចេះសូម្បីតែអាន ឬសរសេរអក្សរ ។ យប់ឡើង កម្មាភិបាលចំនួនប្រាំនាក់បានមកផ្ទះរបស់ឪពុកខ្ញុំ ហើយបានហៅគាត់ទៅក្រៅជាមួយនឹងអ្នកភូមិផ្សេងទៀត ។ ទាំងអស់គ្នាបានឡើងជិះទូក ហើយធ្វើដំណើរតាមទន្លេទៅកាន់កោះ ។ ពេលនោះឪពុករបស់ខ្ញុំគិតថា កម្មាភិបាលទាំងអស់នោះពិតជាបានដឹងពីប្រវត្តិពិតរបស់គាត់ ហើយគាត់កំពុងត្រូវបាននាំយកសម្លាប់ចោល ។ ពេលកំពុងដើរបណ្តើរគិតបណ្តើរ ស្រាប់តែកម្មាភិបាលខ្មែរក្រហមវាយក្បាលអ្នកភូមិម្នាក់នឹងព្រនង់ ហើយអ្នកភូមិនោះក៏បានដួលលើផ្លូវស្លាប់នៅហ្នឹងកន្លែង ។ នៅពេលឪពុករបស់ខ្ញុំឃើញដូច្នេះ គាត់ក៏ទន់ជង្គង់ទៅនឹងដី ដោយភាពតក់ស្លុតហើយនៅស្ងៀមមួយកន្លែង ។ កម្មាភិបាលខ្មែរក្រហមស្រែកគំហកឲ្យឪពុកខ្ញុំ ឲ្យក្រោកឡើង ហើយដើរទៅមុខ ។ ឪពុករបស់ខ្ញុំពិតជាភ័យខ្លាចសឹងតែព្រលឹងហោះចេញពីរូបរាងកាយរបស់គាត់បាត់ទៅហើយ ។ កម្មា-ភិបាលខ្មែរក្រហមគំរាមឪពុកខ្ញុំថា នឹងសម្លាប់គាត់ចោល ប្រសិនបើគាត់ប្រាប់រឿងនេះដល់អ្នកផ្សេង ។ ដូច្នេះគាត់ក៏លាក់នៅក្នុងចិត្តតែម្នាក់ឯង ។

ខ្ញុំបានចាប់កំណើតឡើងប្រាំបីឆ្នាំក្រោយការដួលរលំរបបខ្មែរក្រហម ។ ខ្ញុំធំឡើងដោយមិនដឹងអំពីប្រវត្តិក្រុមគ្រួសាររបស់ខ្ញុំនិងប្រទេសជាតិរបស់ខ្ញុំ ។ តាមរយៈការងារ ខ្ញុំចាប់ផ្តើមសិក្សាអំពីរបបកាចសាហាវនេះ ។ ពីរឆ្នាំបន្ទាប់ពីធ្វើការងារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំត្រូវបានជ្រើសរើសឲ្យចុះធ្វើ

កម្មសិក្សានៅវិទ្យាស្ថាន Shoah Foundation នៃសាកលវិទ្យាល័យ Southern California នៅសហរដ្ឋអាមេរិក ។ ខ្ញុំបានជួបជាមួយនឹងអ្នកដែលរស់រានពីការសម្លាប់របស់ពួកណាស៊ី ដែលមកចែករំលែកនូវបទពិសោធន៍របស់គាត់ ។ លើសនេះទៀតខ្ញុំបានជួបសម្ភាសនឹងខ្មែរសញ្ជាតិអាមេរិកកាំងជាច្រើន ដែលនៅរស់រានមានជីវិត តែមិនត្រលប់មកប្រទេសកំណើតខ្លួនវិញ ។ អ្នកទាំងនោះបង្ហាញពីអារម្មណ៍ភ័យខ្លាច នៅពេលអ្នកទាំងនោះប្រឈមនឹងការចងចាំនូវការបាត់បង់ សាច់ញាតិបងប្អូន និងមិត្តភក្តិ ។

បន្ទាប់ពីការវិលត្រលប់មកកម្ពុជាវិញ ខ្ញុំបានតាំងចិត្តនឹងសម្ភាសឪពុករបស់ខ្ញុំអំពីរឿងរ៉ាវរបស់គាត់ ចាប់ផ្តើមពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ ។ រហូតមកដល់ឥឡូវនេះគឺរយៈពេលបួនឆ្នាំហើយ តែខ្ញុំនៅតែមិនទាន់បានរឿងរ៉ាវរបស់គាត់ទាំងស្រុងទេ ។ គាត់មិនអាចទប់ទឹកភ្នែកបាន នៅពេលគាត់និយាយពីរឿងក្រុមគ្រួសាររបស់គាត់ក្នុងរបបខ្មៅងងឹតនេះ ។ ឥឡូវនេះ គាត់កំពុងឈឺ និងសម្រាកព្យាបាលខ្លួននៅក្នុងមន្ទីរពេទ្យ ។ ខ្ញុំតែងតែរំលឹកប្រាប់គាត់ជារឿយៗអំពីដំណើរការកាត់ទោសខ្មែរក្រហម ព្រោះតែគាត់មានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើបញ្ហានេះ ។ ឪពុករបស់ខ្ញុំបានប្រាប់ថា អ្នករស់រានជីវិតពីរបបខ្មែរក្រហម និងជនជាប់ចោទមួយចំនួនមានវ័យជរា ហើយកំពុងតែស្លាប់ជាបណ្តើរៗ គាត់គ្រាន់តែសង្ឃឹមថា ការប្រកាសសាលក្រមនឹងត្រូវបញ្ចប់មុនពេលអ្នកទាំងអស់នេះលា ចាកពីលោកនេះទៅ ។ មួយថ្ងៃនៅក្នុងគុក មុនពេលមេដឹកនាំទាំងនោះស្លាប់ក៏ជាការបង្ហាញពីការតបស្នងគ្រប់គ្រាន់សម្រាប់គាត់ និងមនុស្សជាទីស្រលាញ់របស់គាត់ ។

ដោយសារតែយើងមិនអាចបំភ្លេចអតីតកាលបាន ការរំលឹកនូវការចងចាំគឺជាកម្លាំងមួយ ដែលជំរុញឲ្យយើងទៅមុខ និងចូលរួមរារាំងមិនឲ្យរបបនេះកើតមានសាជាថ្មីម្តងទៀតនៅពេលអនាគត ។ អ្នកដែលនៅរស់រានមានជីវិតបានចែករំលែកនូវបទពិសោធន៍ និងការចងចាំរបស់ខ្លួនដល់កូនៗ និងចៅៗជំនាន់ក្រោយ ។ ការធ្វើបែបនេះនឹងធ្វើឲ្យក្មេងៗជំនាន់ក្រោយបានដឹងនិងយល់ពីប្រវត្តិរបស់ក្រុមគ្រួសារខ្លួនក៏ដូចជាប្រទេសជាតិរបស់ខ្លួន ។ ក្មេងៗជំនាន់ក្រោយអាចចម្រាញ់យកផលប្រយោជន៍ពីបទពិសោធន៍របស់ចាស់ៗជំនាន់មុន និងសិក្សាពីរឿងទាំងអស់នេះដើម្បីជៀសវាង និងកសាងប្រទេសរបស់ខ្លួនទៅរកការអភិវឌ្ឍនាពេលអនាគត ។ ខ្ញុំនៅតែជឿជាក់ថា ការចងចាំគឺបានដើរតួនាទីយ៉ាងសំខាន់ក្នុងការរឹតចំណងប្រជាជន និងជួយឲ្យប្រជាជនកម្ពុជាបោះជំហានទៅមុខដោយភាពក្លាហានលើសពីការផ្តេកផ្តួលខ្លួនថាជាជនរងគ្រោះក្នុងប្រវត្តិសាស្ត្រនៃវិនាសកម្មនេះ ។

## ៣. គំនិតក្មេងជំនាន់ក្រោយមួយរូបទាក់ទងនឹងសាលាក្តីខ្មែរក្រហម

# ភូល ស្រីនាថ[៨]

នៅពេលមានការនិយាយអំពីការជំនុំជម្រះក្តីខ្មែរក្រហមម្តងៗ សំណួរជាច្រើនត្រូវបានលើកមកនិយាយដូចជា តើអ្វីជាភាពចាំបាច់របស់អង្គជំនុំជម្រះចំពោះអ្នកដែលរស់រានមានជីវិតក្រោយរបបខ្មែរក្រហម ចំពោះប្រជាជនកម្ពុជា និងចំពោះជាតិទាំងមូល? ហើយថា តើការកាត់ក្តីនេះពិតជានាំមកនូវយុត្តិធម៌មែនឬទេ? បុគ្គលម្នាក់ៗតែងតែមានគំនិតផ្សេងៗគ្នា ។ តាមការយល់ឃើញជាប្រវត្តិសាស្ត្រនោះ រាល់អ្វីដែលបានកើតឡើង និងកំពុងបន្តកើតឡើងនៅអង្គជំនុំជម្រះក្តី ដើរតួនាទីយ៉ាងសំខាន់នៅក្នុងប្រវត្តិសាស្ត្រកម្ពុជាបច្ចុប្បន្ន ។

តុលាការខ្មែរក្រហម គឺពិតជាមានសារៈសំខាន់ ដោយសារតែតុលាការនេះនាំមកនូវការស្វែងរកការពិតជូនជាតិ ជនរងគ្រោះ ដើម្បីរំឭកអតីតកាល ធ្វើការផ្សះផ្សា និងជាសះស្បើយផ្លូវចិត្ត ។ ទាំងនេះហើយ ជាអ្វីដែលតុលាការខ្មែរក្រហមបានធ្វើ ។ គួរបញ្ជាក់ផងដែរថា ករណីសំណុំរឿង០០១ បានបញ្ចប់ទៅ ដោយមានការដាក់ទោសឲ្យជាប់គុកមួយជីវិតចំពោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលធ្លាប់កាន់កាប់នៅគុកទួលស្លែងឬមន្ទីរស-២១ ។ ការកាត់ទោសនេះ បើកចំហរជាផ្លូវការដើម្បីឲ្យជនរួមជាតិទាំងអស់ស្វែងរកបាននូវយុត្តិធម៌នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានបំផ្លាញជីវិតរស់នៅរបស់ប្រជាជនកម្ពុជាទាំងមូល ។ ស្របពេលនេះដែរ ករណីសំណុំរឿង០០២រឹតតែមានសារៈសំខាន់ ដោយសារតែជនជាប់ចោទទាំងអស់ ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការអនុវត្តនូវគោលនយោបាយសម័យកម្ពុជាប្រជាធិបតេយ្យនាំឲ្យជួបវិបត្តិ សម្លាប់មនុស្សប្រមាណជា ១លាន៧សែននាក់ ។[៩] ចំនួនទឹកប្រាក់ដែលបានចំណាយចាប់តាំងពីបង្កើតសាលាជំនុំជម្រះក្តីក៏បង្ហាញឲ្យឃើញនូវសារៈសំខាន់ដែរ ។ រហូតមកដល់ពេលនេះ ចំនួនទឹកប្រាក់សរុបដែលបានចំណាយគឺ ២០៨,៧លានដុល្លារ[១០] ចាប់តាំងពីឆ្នាំ២០០៦ បង្ហាញឲ្យឃើញថា រាល់ភាគីទាំងអស់មានឆន្ទៈក្នុងការផ្តល់ជំនួយដល់សាលាជំនុំជម្រះក្តីដើម្បីសម្រេចឲ្យបាននូវយុត្តិធម៌ ។

---

[៨] ភូល ស្រីនាថ ទទួលបានបរិញ្ញាបត្រពីសកលវិទ្យាល័យ Redlands នៅក្នុងរដ្ឋ California មុខវិជ្ជា “Nature of Imbalance: East Asian Politics and Media ” ការបញ្ចប់ការសិក្សាដោយកិត្តិយស ក្នុងមុខវិជ្ជាទំនាក់ទំនងអន្តរជាតិ ។ រហូតមកដល់ខែធ្នូឆ្នាំ២០១៣ ស្រីនាថ កំពុងធ្វើជាបុគ្គលិកស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារកម្ពុជា នៅទីក្រុងភ្នំពេញ ។

[៩] ការវាយតម្លៃរបស់សាស្ត្រាចារ្យ ប៊ែន គៀរនិន ។

[១០] មើល *ECCC at a Glance* (តុលា ២០១៣), នៅគេហទំព័រ http://www.eccc.gov.kh/sites/default/files/ECCC%20at%20a%20Glance_ENG_Oct_2013.pdf.

ប៉ុន្តែមិនមែនគ្រប់គ្នាសុទ្ធតែយល់ដូច្នេះទេ ។ អ្នកធ្វើការនៅតុលាការកាត់ទោសខ្មែរក្រហមប្រហែល ជាមិនចង់ឮការយល់ឃើញរបស់ម្ដាយខ្ញុំទេ ។ ម្ដាយរបស់ខ្ញុំក៏ជាជនរងគ្រោះម្នាក់នៅក្នុងរបបខ្មែរក្រហម ។ គាត់មានអាយុតែ៦ ឬ៧ឆ្នាំក្នុងរបបនោះ ហើយគាត់សំណាងណាស់ដែលមិនត្រូវបានបំបែកចេញពីជីដូនរបស់ខ្ញុំ ដូចក្មេងៗដទៃទៀត ។

នៅក្នុងការសន្ទនាជាច្រើនជាមួយនឹងគាត់អំពីសាលាជំនុំជម្រះក្ដី ម្ដាយខ្ញុំបានប្រាប់ថា គាត់មិនបានដឹងអំពីសាលាជំនុំជម្រះក្ដីខ្មែរក្រហម ហើយដោយសារហេតុនេះហើយបានជាគាត់មិនបានយកចិត្តទុកដាក់ ឬខ្វល់ខ្វាយអំពីការកាត់ក្ដីនេះ ។ ខ្ញុំសឹងតែមិនជឿលើអ្វីដែលគាត់បានប្រាប់ព្រោះថា ម្ដាយរបស់ខ្ញុំតែងតែតាមដាន នូវព័ត៌មានក្នុងប្រទេសកម្ពុជាចុះហេតុអ្វីបានជាគាត់បែរជាមិនដឹងអំពីការជំនុំជម្រះក្ដីទៅវិញ ។ ទោះជាគាត់ប្រាប់ថា គាត់មិនបានតាមដានការជំនុំជម្រះក្ដីក៏ដោយ គាត់មិនជឿថាការជំនុំជម្រះក្ដីពិតជានាំមកនូវលទ្ធផលដែលគួរចង់បាននោះទេ ។ គាត់និយាយទៀតថា យើងបានចំណាយពេលវេលាយូរពេកហើយចំពោះការជំនុំជម្រះក្ដីនេះ ហើយយើងក៏បានចំណាយលុយច្រើនណាស់ដែរ តែមិនទាន់មានលទ្ធផលអ្វីគួរឲ្យពេញចិត្តសោះ ។ ដោយយល់ពីហេតុផលរបស់ម្ដាយ ខ្ញុំក៏បន្តសួរគាត់ទៀតថា តើគាត់គិតថាយើងពិតជាអាចរកយុត្តិធម៌បានមកពីការជំនុំជម្រះក្ដីនេះដែរទេ គាត់ឆ្លើយភ្លាមថា “មិនអាចទេ” ។

ប្អូនស្រីពៅរបស់យាយខ្ញុំមានគំនិតខុសប្លែកពីម្ដាយរបស់ខ្ញុំ ។ សព្វថ្ងៃនេះ គាត់មានអាយុជាង ៥០ឆ្នាំ ហើយបទពិសោធន៍របស់គាត់នៅក្នុងរបបខ្មែរក្រហមបានបន្សល់ទុកនូវការចងចាំយ៉ាងជ្រាលជ្រៅ ។ មិនខុសប្លែកពីរឿងរ៉ាវរបស់ប្រជាជនមួយចំនួនដែលបានរៀបរាប់ គាត់ត្រូវបានជម្លៀសទៅខេត្តក្រចេះ ហើយត្រូវបង្ខំឲ្យធ្វើស្រែ ជីកប្រឡាយ និងសាងសង់ទំនប់ទឹក ។ ការរស់នៅរបស់គាត់លំបាកខ្លាំងណាស់ ដែលធ្វើឲ្យជីវិតរបស់គាត់ប្រែប្រួលរហូតមកដល់សព្វថ្ងៃនេះ ។

គាត់ពិតជានារីម្នាក់ដែលគួរឲ្យសរសើរ ដោយសារតែគាត់សកម្មនៅក្នុងឆាកនយោបាយ គាត់គាំទ្រខ្លាំងក្លាលើយុត្តិធម៌សង្គម ។ ចាប់តាំងពីថ្ងៃដំបូងនៃការបើកសំណុំរឿង០០១ គាត់បានតាមដានរហូត ។ គាត់ជឿជាក់ថា ការជំនុំជម្រះក្ដីគឺមានសារៈសំខាន់ណាស់សម្រាប់គាត់ និងប្រទេសជាតិ ។ គាត់យល់ថា សាលាជំនុំជម្រះក្ដីនេះមានតួនាទីត្រួសត្រាយផ្លូវទៅរកយុត្តិធម៌ជូនប្រទេសជាតិ ។

ប៉ុន្តែដូចនឹងអ្វីដែលម្ដាយរបស់ខ្ញុំបានលើកឡើងនៅខាងដើម លោកយាយរបស់ខ្ញុំគិតថា ដំណើរការរបស់សាលាក្ដីនេះដើរយឺតពេក ហើយជនជាប់ចោទ ក៏កាន់តែចាស់ពីមួយថ្ងៃទៅមួយថ្ងៃ និងខិតចូលសេចក្ដីស្លាប់ជាបណ្ដើរៗ ។ គាត់បញ្ជាក់ពីការខកចិត្តពាក់ពន្ធ័នឹងការស្លាប់របស់ អៀង សារី និងការដោះលែង អៀង ធីរិទ្ធ ដោយជំងឺផ្លូវចិត្តរបស់គាត់ ប៉ុន្តែគាត់បញ្ជាក់ដែរថា ដំណើរការនេះមិន

អាចប្រញាប់ប្រញាល់បានទេដោយសារតែពាក់ព័ន្ធនឹងដំណើរការច្បាប់ ។ គាត់នៅតែមានះហើយពោលថា ការជំនុំជម្រះក្តីនេះមិនអាចផ្តល់យុត្តិធម៌១០០ភាគរយដល់គាត់និងប្រជាជនកម្ពុជានោះទេ ។ ទោះបីជាអ៊ីចឹងក៏ដោយគាត់សង្ឃឹមថា ជនរងគ្រោះទាំងអស់នឹងមានសន្តិភាពផ្លូវចិត្តបានខ្លះ និងពេញចិត្តនឹងការសម្រេចរបស់តុលាការ ប្រសិនបើសាលក្រមចុងក្រោយបានឆ្លុះបញ្ចាំងពីទម្ងន់នៃឧក្រិដ្ឋកម្មដែលជនជាប់ចោទបានប្រព្រឹត្ត ។ ការកាត់ទោសឲ្យជាប់គុកអស់មួយជីវិតគឺជាអ្វីដែលគាត់សង្ឃឹមថាជនជាប់ចោទនឹងទទួល ។

ការជំនុំជម្រះក្តីអតីតមេដឹកនាំខ្មែរក្រហមពីររូបដែលនៅរស់ គឺមានសារៈសំខាន់ខ្លាំងណាស់សម្រាប់រូបគាត់ ប៉ុន្តែនេះគឺមិនទាន់គ្រប់គ្រាន់ទេ ។ គាត់ចង់ឲ្យសាលាជំនុំជម្រះក្តីបន្តការស៊ើបអង្កេតអ្នកដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការសម្លាប់មនុស្សនៅតាមតំបន់ក៏ដូចជានៅថ្នាក់ឃុំ ។ គាត់ផ្តល់ជាតម្រុយថា ឲ្យនាំយកមកកាត់ទោសរាល់អ្នកពាក់ព័ន្ធទាំងអស់ទោះជាអ្នកមានអំណាចក៏ដោយ ។ ការជឿបែបនេះនឹងជួយរារាំងមិនឲ្យឧក្រិដ្ឋជនរួចផុតពីអំពើឃោរឃៅដែលខ្លួនបានប្រព្រឹត្ត និងជាគំរូដល់អ្នកដឹកនាំជំនាន់ក្រោយមិនឲ្យប្រព្រឹត្តអំពើព្រៃផ្សៃដូច្នេះ ព្រោះមានយន្តការផ្សេងៗសម្រាប់ដាក់ទោសអ្នកដែលប្រព្រឹត្តឧក្រិដ្ឋកម្ម ។

ជីតារបស់ខ្ញុំក៏បានចែករំលែកនូវមតិយោបល់ស្រដៀងទៅនឹងប្អូនស្រីយាយរបស់ខ្ញុំដែរ ។ នៅពេលដែលខ្ញុំស្នើគាត់ឲ្យរៀបរាប់ពីគំនិតរបស់គាត់ គាត់ប្រាប់ខ្ញុំថា គាត់គាំទ្រយ៉ាងពេញទំហឹងចំពោះសាលាជំនុំជម្រះក្តីខ្មែរក្រហម ហើយដូចជនរងគ្រោះផ្សេងទៀតក្នុងរបបខ្មែរក្រហមដែរ គាត់ចង់ឃើញជនដែលធ្វើឲ្យគាត់រងទុក្ខវេទនាសាកសមនឹងទទួលខុសត្រូវនូវអ្វីដែលអ្នកនោះបានប្រព្រឹត្ត ។

ខ្ញុំយល់ថា រឿងរ៉ាវរបស់តាខ្ញុំគួរតែត្រូវចែករំលែកដល់សាធារណជន ។ គាត់មានស្រុកកំណើតនៅខេត្តស្វាយរៀង ហើយគាត់បានប្តូរទីលំនៅមកកាន់ទីក្រុងភ្នំពេញនៅទសវត្សរ៍៥០ តាមឪពុកម្តាយរបស់គាត់ដើម្បីរកការងារធ្វើ ។ តារបស់ខ្ញុំរៀនបានជ្រៅជ្រះណាស់ ទោះបីជាពេលនោះគាត់មកពីគ្រួសារដែលមិនសូវធូរធារក៏ដោយ ប៉ុន្តែគាត់បានបំពេញការសិក្សានៅគ្រប់កម្រិតទាំងអស់ដែលសាលាប្រគល់ឲ្យ ។ បន្ទាប់មក គាត់បម្រើការងារនៅស្ថានទូតអាមេរិកក្នុងឋានៈជាលេខាការិយា-ល័យរហូតដល់ពេលដែល សម្តេចព្រះ នរោត្តម សីហនុ បញ្ចប់រាល់ទំនាក់ទំនងជាមួយនឹងសហរដ្ឋអាមេរិក ។ គាត់ត្រលប់មកបម្រើការងារនៅស្ថានទូតម្តងទៀតនៅពេលមានទំនាក់ទំនងឡើងវិញ ។ លើកនេះ គាត់បម្រើការជាអ្នកកាន់វិទ្យុទាក់ទងខាងយោធា ។ គ្រាមួយ គាត់ប្រាប់ខ្ញុំថា គាត់ធ្វើការត្រួតពិនិត្យលើឃ្លាំងទំនិញរបស់ទ័ពអាមេរិកនៅក្នុងតំបន់អន្លង់វែង ដែលជាផ្នែកមួយនៃក្រុមប្រឹក្សាជំនួយទ័ពអាមេរិក (US Military Assistance Advisory Group) ។

ជីតារបស់ខ្ញុំឆ្លាត និងមានសំណាង ។ នៅក្នុងរបបខ្មែរក្រហម គាត់គួរតែជាមនុស្សដំបូង ដែលត្រូវខ្មែរក្រហមសម្លាប់ ដោយសារតែគាត់មានសមត្ថភាព និងមានទំនាក់ទំនងជាមួយនឹងសហរដ្ឋអាមេ- រិក ។ គាត់ត្រូវបានកម្មាភិបាលខ្មែរក្រហមចាប់ដាក់គុក និងបង្ខំឲ្យធ្វើការធ្ងន់ ។ រយៈពេលមួយខែក្រោយមក អង្គការដោះលែងគាត់ដោយសារឃើញថាគាត់ជាមនុស្សធម្មតា ។ លើកទីពីរនោះ កម្មា- ភិបាលខ្មែរក្រហម បានយកគាត់ទៅឆ្ងាយពីភូមិនៅពេលដែលកម្លាំងទ័ពវៀតណាមចូលមកប្រទេសកម្ពុជា ។ អង្គការត្រូវការមនុស្សបន្ថែមដើម្បីចម្អិន និងនាំយកអ្នករបួស និងអ្នកស្លាប់ពីសមរភូមិ ។

ជារៀងរាល់ថ្ងៃ ជីតារបស់ខ្ញុំតាមដានតាមសារព័ត៌មានអន្តរជាតិនានាដែលបានចាក់ផ្សាយជាប្រចាំអំពីអ្វីៗដែលបានកើតឡើងនៅជុំវិញពិភពលោក ។ គាត់អានឯកសារនានាដែលទាក់ទងទៅនឹងខ្មែរក្រហមដើម្បីព្យាយាមសិក្សាអំពីអ្វីដែលធ្លាប់បានកើតឡើង និងស្វែងរកនូវព័ត៌មានថ្មីៗ ។ នៅចុងបញ្ចប់ តាមការសម្ភាសន៍ជាមួយគាត់ គាត់ប្រាប់ខ្ញុំថា ដំណើរការជំនុំជម្រះក្តីខ្មែរក្រហម គឺជាមធ្យោបាយមួយសម្រាប់ដាក់អតីតមេដឹកនាំខ្មែរក្រហមឲ្យទទួលខុសត្រូវ និងដាក់ទណ្ឌកម្មចំពោះបទឧក្រិដ្ឋរបស់មេដឹកនាំទាំងនោះតាមផ្លូវច្បាប់ ។ មិនខុសពីជីដូនរបស់ខ្ញុំប៉ុន្មានទេជីតាខ្ញុំយល់ឃើញថា ដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញរបស់តុលាការកម្ពុជាគឺពិតជាយឺតពេក ហើយគាត់សង្ឃឹមថា ដំណើរការនឹងលឿនជាងនេះព្រោះថាអតីតមេដឹកនាំខ្មែរក្រហមកាន់តែមានវ័យចំណាស់ ។ ដោយឡែកគាត់នៅតែចង់ឃើញអតីតមេដឹកនាំខ្មែរក្រហមត្រូវបានកាត់ទោសឲ្យជាប់គុកអស់មួយជីវិត ទោះបីជាមេដឹកនាំទាំងនោះមិនអាចរស់នៅបានយូរប៉ុន្មានក៏ដោយ ។ សម្រាប់ជីតារបស់ខ្ញុំ ការកាត់ទោសបែបនេះគឺជានិមិត្តរូបតំណាងឲ្យយុត្តិធម៌ ។ គាត់ជឿជាក់ទៀតថា ការជំនុំជម្រះក្តីនេះក៏ជាផ្លូវមួយដែលបង្ហាត់បង្រៀនដល់ក្មេងៗជំនាន់ក្រោយពីអ្វីៗដែលបានកើតឡើង ក៏ដូចជារំឭកដល់អ្នកដឹកនាំនៅពេលអនាគតអំពីអំពើអាក្រក់ដែលបានកើតឡើង និងកេរតំណែលផ្សារភ្ជាប់តមកដែលនឹងបង្រៀន និងរារាំងក្មេងជំនាន់ក្រោយ មិនឲ្យដើរតាមផ្លូវដដែលនាពេលអនាគត ។

ខ្ញុំក៏ជាក្មេងម្នាក់ ក្នុងចំណោមអ្នកដែលបានកើតនៅសម័យចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ។ នៅពេលដែលខ្ញុំរស់នៅក្នុងប្រទេសកម្ពុជា ខ្ញុំស្ទើងតែមិនដឹងអ្វីទាំងអស់ពីរបបខ្មែរក្រហម ។ អ្វីទាំងអស់ដែលខ្ញុំធ្លាប់ដឹង គឺសម័យ ប៉ុល ពត គឺអាក្រក់ ប៉ុន្តែខ្ញុំមិនច្បាស់ថា ប៉ុល ពត គឺជាមនុស្ស ឬជាអ្វីផ្សេងនោះទេ ។ មិនយូរប៉ុន្មាន នៅពេលដែលខ្ញុំទៅរស់នៅសហរដ្ឋអាមេរិក ខ្ញុំសិក្សាពីអ្វីដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ។ ដំបូងពិតជារន្ធត់ណាស់ សិក្សាពីអំពើព្រៃផ្សៃទាំងនេះ ហើយប្រវត្តិសាស្ត្រនេះហាក់ដូចជាមិនគួរឲ្យជឿទាល់តែសោះ ។ តែបន្ទាប់ពីបានសិក្សាកាន់តែលម្អិតពីភាពឈឺចាប់គ្រប់បែបយ៉ាង ការបំផ្លិចបំផ្លាញនៅក្នុងរបបខ្មែរក្រហមញ៉ាំញីប្រទេសកម្ពុជា

និងបានយល់ដឹងបន្ថែមពីក្រុមគ្រួសារ ខ្ញុំចាប់ផ្តើមជឿជាក់ថាសម័យខ្មែរក្រហមគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ ដោយសារប្រវត្តិសាស្ត្រនេះជួយឲ្យមនុស្សជាតិចាប់ផ្តើមសិក្សា និងយល់ពីអតីតកាល និងជំរុញឲ្យមានការពិភាក្សាដើម្បីរកមធ្យោបាយផ្សះផ្សាជាមួយនឹងអតីតកាលជាសះស្បើយ និងការរីកលូតលាស់ទៅមុខនាពេលអនាគត ។ ខ្ញុំក៏យល់ឃើញដូចជាម្តាយរបស់ខ្ញុំដែរ ខ្ញុំគិតថា ដំណើរការរបស់សាលាក្តីខ្មែរក្រហមពិតជាយឺតណាស់ ហើយខ្ញុំមានអារម្មណ៍ក្រេវក្រោធចំពោះដំណើរការនេះ ដោយក្តីបារម្ភចំពោះអតីតមេដឹកនាំខ្មែរក្រហមនឹងស្លាប់មុនពេលទទួលបានការកាត់ទោសសម្រាប់ឧក្រិដ្ឋកម្មដែលបានកើតឡើង ។

លើសពីនេះ ខ្ញុំក៏មិនពេញចិត្តនឹងភាពរសើបផ្នែកនយោបាយដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជួបប្រទះ ដែលកាន់តែបន្តភាពយឺតយ៉ាវ ។ ផ្ទុយទៅវិញ ទាំងនេះគឺមិនមែនជាបញ្ហាចម្បងចំពោះការឡើយណាយរបស់ខ្ញុំទេ ខ្ញុំរំពឹងឲ្យតុលាការបន្តការស៊ើបអង្កេតឲ្យបានទូលំទូលាយនូវអ្វីដែលបានកើតឡើងនៅចន្លោះឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។ ការរំពឹងទុករបស់ខ្ញុំនេះសង្ឃឹមថា តុលាការនឹងព្យាយាមក្រលេកមើលបញ្ហាជាសកល និងដាក់អ្នកនៅខាងក្រៅឲ្យទទួលខុសត្រូវដែរ ។ ខ្ញុំគិតថា មិនមែនមានតែអតីតមេដឹកនាំខ្មែរក្រហមទេដែលត្រូវយកមកជំនុំជម្រះ ។ ជនដែលជាប់ពាក់ព័ន្ធមានជាច្រើនទៀតដែលមានកំហុសដូចគ្នាដែរ ដែលបណ្តោយឲ្យរបបនេះកើតឡើង ។ រហូតមកដល់ពេលនេះ ជនរួមជាតិទាំងអស់ កំពុងតែរង់ចាំនូវការប្រកាសសាលក្រមលើសំណុំរឿង០០២ ជាមួយនឹងការរំពឹងទុកផ្សេងៗគ្នា ។ ខ្ញុំដឹងថាការរំពឹងទុករបស់ខ្ញុំមិនអាចសម្រេចបាន និងថាភាពឡើយណាយរបស់ខ្ញុំចំពោះតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម និងអារម្មណ៍ថាយុត្តិធម៌មិនអាចសម្រេចបាននេះនឹងនៅមានជាបន្ត ។

## ៨. ឪពុករបស់ខ្ញុំ និងការជំនុំជម្រះក្តីកាំង ហ្គេកអ៊ាវ ហៅ ឌុច

ហ៊ុយ សេងហ៊ុល[១១]

ខ្ញុំកើតនៅឆ្នាំ១៩៩២ នៅស្រុកកោះធំ ខេត្តកណ្តាល ហើយមានបងប្អូនប្រាំបួននាក់ ។ ខ្ញុំជាកូនទីបួននៅក្នុងគ្រួសារ ។ ឪពុករបស់ខ្ញុំឈ្មោះ ហ៊ឹម ហ៊ុយ ដែលមនុស្សភាគច្រើនស្គាល់គាត់ថា ជា

[១១] ហ៊ុយ សេងហ៊ុល គឺជាសមាជិកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ធ្វើការលើគម្រោងសៀវភៅនៃការចងចាំ និងជានិស្សិតច្បាប់ឆ្នាំទីបីនៅសកលវិទ្យាល័យអាស៊ីអ៊ឺរ៉ុប ។

អតីតសន្តិសុខមួយរូបនៅមន្ទីរស-២១ ដែលមាន កាំង ហ្គេកអ៊ាវ ហៅ ឌុច ជាប្រធាន។ នៅក្នុងរបបខ្មែរក្រហម មនុស្សជាច្រើនត្រូវបានចាប់ខ្លួនហើយដាក់ឃុំឃាំងនៅមន្ទីរស-២១ដែលក្រោយមកអ្នកទោសស្ទើរតែទាំងអស់ត្រូវបានសម្លាប់ចោល ។ កាលពីមុន ខ្ញុំមិនសូវបានដឹងអំពីរឿងរ៉ាវទាំងអស់ដែលបានកើតឡើងនៅសម័យខ្មែរក្រហមប៉ុន្មានទេ បើទោះបីជាឪពុកម្តាយខ្ញុំធ្លាប់ទទួលរងនូវភាពលំបាកវេទនាកាលពីសម័យនោះក៏ដោយ ។ រហូតដល់ពេលដែលរឿងរ៉ាវនៃរបបខ្មែរក្រហមត្រូវបានមនុស្សជាច្រើននិយាយឡើងវិញ និងរហូតដល់ពេលដែលខ្ញុំបានចូលមកបម្រើការងារជាបុគ្គលិកស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំបានចាប់ផ្តើមស្វែងយល់ពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបនេះ ។

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសប្រជាជនដែលរស់នៅទីក្រុងភ្នំពេញឲ្យទៅនៅតាមជនបទដើម្បីធ្វើស្រែចម្ការ ហើយអ្នកទាំងនោះត្រូវបានបំបែកចេញពីឪពុកម្តាយនិងកូន ។ ខ្មែរក្រហមបានបង្ខំឲ្យប្រជាពលរដ្ឋធ្វើការស្ទើរគ្មានពេលសម្រាក និងពុំមានអាហារបរិភោគគ្រប់គ្រាន់ឡើយ ។ ប្រជាពលរដ្ឋទទួលបានតែបបររាវតែមួយឬពីរវែកប៉ុណ្ណោះក្នុងមួយពេល ។ កុមារមិនបានរៀនសូត្រទេ ។ កុមារត្រូវបានចាត់តាំងឲ្យដើររើសអាចម៍គោ និងឃ្វាលគោក្របីទៅវិញ ។

ខ្ញុំបានរៀនសូត្រពីរឿងរ៉ាវ នៃរបបខ្មែរក្រហមពីឪពុករបស់ខ្ញុំ និងពីមជ្ឈមណ្ឌលឯកសារកម្ពុជាដែលខ្ញុំកំពុងធ្វើការទាក់ទងនឹងរឿងរ៉ាវដែលបានកើតឡើងកាលពីរបបខ្មែរក្រហម ។ ឪពុករបស់ខ្ញុំមានការសោកស្តាយជាខ្លាំង ហើយរឿងរ៉ាវទាំងនេះនៅតែដក់ជាប់ក្នុងចិត្តរបស់ឪពុកខ្ញុំជានិច្ច ។ គាត់តែងតែនិយាយប្រាប់ខ្ញុំថា គាត់មិនដែលគិតថានឹងអាចមានជីវិតរស់ចេញពីរបបខ្មែរក្រហមទេ ។ វាជាការចងចាំដ៏ឈឺចាប់បំផុតសម្រាប់ពុកចំពោះអ្វីដែលបានកើតឡើង ជាពិសេសរឿងរ៉ាវដែលបានកើតឡើងនៅមន្ទីរសន្តិសុខស-២១ ។ នៅមន្ទីរស-២១ ពេលខ្លះពុកមានបំណងចង់ធ្វើអត្តឃាតខ្លួនឯង ដោយសារតែមិនអាចទ្រាំបាន ។ ប៉ុន្តែគាត់ក៏ដឹងដែរថាប្រសិនបើគាត់សម្រេចចិត្តបែបនោះមែន នោះក្រុមគ្រួសាររបស់គាត់ក៏នឹងមានជោគវាសនាដូចជាគាត់ដែរ ពុក និងកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមផ្សេងទៀតគ្មានជម្រើសអ្វីទេនៅក្នុងរបបខ្មែរក្រហម ។ អ្នកទាំងអស់គ្នាត្រូវតែស្តាប់បញ្ជា និងគោរពតាមថ្នាក់លើជាដាច់ខាត ។ ឌុច ជាប្រធានរបស់ ពុក ។ ឌុច ជាមនុស្សតែម្នាក់ដែលគួរតែទទួលខុសត្រូវចំពោះរឿងរ៉ាវដែលបានកើតឡើងនៅមន្ទីរសន្តិសុខស-២១ ។

បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំនៅឆ្នាំ១៩៧៩ ពុកត្រូវបានគណៈកម្មាធិការស្រុកកោះធំហៅយកទៅអប់រំរៀនសូត្រអស់រយៈពេលជាងមួយឆ្នាំពីបទជាប់ពាក់ព័ន្ធនឹងរបបខ្មែរក្រហម ។ ក្រោយមកគ្រួសាររបស់ខ្ញុំក៏បានជួបជុំគ្នាវិញបន្ទាប់ពីពុកត្រូវបានដោះលែងឲ្យចេញពីមន្ទីរឃុំឃាំងស្រុកកោះធំ ។ ជារឿយៗ ពុកនិយាយប្រាប់ខ្ញុំថា អ្វីដែលគាត់បានធ្វើកាលពីរបបខ្មែរក្រហម គឺដើម្បីតែរស់តែ

ប៉ុណ្ណោះ ។ បើសិនជាគាត់មិនធ្វើគាត់នឹងត្រូវស្លាប់ ។ បន្ទាប់ពីពុកត្រូវបានដោះលែងខ្ញុំបានសង្កេតឃើញថាពុកនៅតែមានការសោកស្តាយចំពោះរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ ទោះបីជាយ៉ាងណាក៏ដោយ ពុកនៅតែខិតខំប្រឹងប្រែងដើម្បីចិញ្ចឹមបីបាច់គ្រួសារតាមសមត្ថភាពដែលគាត់ធ្វើបាន ។ ពុកខ្ញុំគឺជាមនុស្សខុសប្រាហ៍ព្យាយាម ។ គាត់ធ្វើស្រែចម្ការដើម្បីជីវភាពគ្រួសារក្រីក្រមួយនេះ ។ ឥឡូវដោយសារតែពុក ជីវភាពរបស់យើងហាក់ដូចជាប្រសើរជាងមុន ។ បងៗរបស់ខ្ញុំមួយចំនួនបានរៀបការនិងមានមុខរបបចិញ្ចឹមជីវិតរៀងៗខ្លួន ។ ខ្ញុំក៏បានរៀនបន្តនៅសកលវិទ្យាល័យនៅទីក្រុងភ្នំពេញ ។ ឪពុករបស់ខ្ញុំស្រឡាញ់កូនៗណាស់ ។ គាត់មិនដែលធ្វើបាបប្តូវាយដំកូនឡើយ ។ គាត់តែងតែនិយាយថា គាត់មិនចង់ឃើញកូនរបស់គាត់មានវាសនា ដូចជារូបគាត់កាលពីរបបខ្មែរក្រហមនោះទេ ។ អ្នកជិតខាងស្រឡាញ់រាប់អានពុកគ្រប់ៗគ្នា ។ ពុកមិនដែលបង្កទំនាស់ជាមួយអ្នកដទៃឡើយហើយដោយសារតែដើរតាមគំរូរបស់ពុក កូនៗក៏មិនដែលនាំរឿងមិនល្អ ឬបង្កបញ្ហាអ្វីឲ្យពុកវិញដែរ ។

ខ្ញុំស្អប់ ឌុច ។ ខ្ញុំស្អប់នូវអ្វីដែលគាត់ បានប្រព្រឹត្តកាលពីរបបខ្មែរក្រហម ។ ខ្ញុំចង់ឲ្យ ឌុច ជាប់ទោសអស់មួយជីវិត ហើយមិនគួរត្រូវបានបន្ធូរបន្ថយទោសនោះទេ ។ ខ្ញុំគិតថាប្រសិនបើរបបខ្មែរក្រហមមិនបានកើតឡើងនោះទេ ស្ថានភាពគ្រួសារខ្ញុំប្រហែលជាល្អប្រសើរជាងនេះពីព្រោះ យើងមិនចាំបាច់ចាប់ផ្តើមកសាងជីវិតសាជាថ្មីបន្ទាប់ពីរបបខ្មែរក្រហមនោះទេ ។ ឌុច មិនមែនត្រឹមតែជាប្រធានមន្ទីរស-២១ និងជាប្រធានរបស់ពុកខ្ញុំប៉ុណ្ណោះនោះទេ ឌុច ថែមទាំងជាអ្នកដែលមើលការខុសត្រូវបន្ថែមទៅលើមន្ទីរសន្តិសុខស-២៨ ឬគុកព្រៃស និងវាលពិឃាតជើងឯកដ៏គួរឲ្យរន្ធត់ ។ ឌុច គឺជាជនបដិវត្តន៍ដ៏កំណាចម្នាក់ ។ ឌុច ជាអ្នកទទួលខុសត្រូវនៃជីវិតមនុស្សប្រមាណជាងមួយម៉ឺនបួនពាន់នាក់ដែលក្នុងនោះរួមមានកុមារជាច្រើននាក់ផង ដែលបានស្លាប់នៅក្រោមការគ្រប់គ្រងរបស់គាត់ ។

នៅខែកុម្ភៈ ឆ្នាំ២០១២ ខ្ញុំបានធ្វើដំណើរទៅកាន់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមជាមួយពុករបស់ខ្ញុំ ដើម្បីចូលរួមស្តាប់ការប្រកាសសាលក្រមលើបណ្តឹងឧទ្ធរណ៍លើសំណុំរឿង០០១ ដែលមានជនជាប់ចោទឈ្មោះ ឌុច ។ ខ្ញុំមានការបារម្ភក្នុងចិត្ត ប្រសិនបើ ឌុច មិនត្រូវបានតុលាការកំពូលដាក់ទោសអស់មួយជីវិត ។ ប៉ុន្តែ នៅពេលដែលបានឮការប្រកាសរបស់តុលាការកំពូលថា ដាក់ទោស ឌុច អស់មួយជីវិត ខ្ញុំមានការសប្បាយចិត្តជាខ្លាំង ព្រោះដូចទៅនឹងអ្វីដែលខ្ញុំបានរំពឹងទុក ។ ខ្ញុំពេញចិត្តនឹងការសម្រេចនេះ ហើយឪពុករបស់ខ្ញុំដែលបានមកស្តាប់ការប្រកាសសាលក្រមជាមួយខ្ញុំក៏មានការសប្បាយរីករាយដែរ ។ ទីបំផុត ឌុច ត្រូវតែទទួលខុសត្រូវចំពោះទង្វើរបស់គាត់ ។